**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គ.ជ.អ.ប
NCDD

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ**
**តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤

# សេចក្តីប្រកាសព័ត៌មាន
# កិច្ចប្រជុំលើកទី១០ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សូមជូនដំណឹងដល់បណ្តាញសារព័តិមានទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា គ.ជ.អ.ប នឹងរៀបចំកិច្ចប្រជុំលើកទី១០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប ។**

កិច្ចប្រជុំលើកទី១០នេះមានរបៀបវារៈដូចជា៖

1. ពិភាក្សា និងអនុម័តលើសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំលើកទី៩ របស់ គ.ជ.អ.ប
2. ពិភាក្សា និងអនុម័តលើសេចក្តីព្រាងផែនការអនុវត្តរយៈពេល៣ឆ្នាំ (២០១៥-២០១៧) ដំណាក់កាលទី២ (ផអ៣ទី២) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
3. ពិភាក្សាអំពីកិច្ចដំណើរការផ្ទេរមុខងារ និងធនធានពីក្រសួង ស្ថាប័នអោយទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និង
4. បញ្ហាផ្សេងៗទៀត

កិច្ចប្រជុំនេះនឹងមានការចូលរួមពីតំណាងក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលដែលជាសមាជិក គ.ជ.អ.ប តំណាងក្រសួង ស្ថាប័នអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តំណាងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធនានាសរុបចំនួនប្រមាណ ៩០រូប ។

**ទីកន្លែង:** នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ (អគារ S)
អាសយដ្ឋាន: មហាវិថីព្រះនរោត្តម ខណ្ឌចំការមន រាជធានីភ្នំពេញ
**ពេលវេលា:** ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ចាប់ពីម៉ោង ២:០០រសៀល ដល់ម៉ោង ៥:៣០ ល្ងាច

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីដែលជាអ្នកសារព័ត៌មាន ចូលរួមយកព័ត៌មានកុំបីខាន។

*ព័ត៌មានបន្ថែម សូមទំនាក់ទំនងលេខាធិការដ្ឋាន គ.ជ.អ.ប*
*តាមរយៈលេខទូរស័ព្ទ ០១២ ៧៥៨ ៥២០*
*E-mail: kimchung@ncdd.gov.kh*
*Website: www.ncdd.gov.kh*